# សមាគមជាតក្រុមប្រឹក្សារាជធានី ខេត្ត

# ក្រមសីលធម៌
# របស់
# សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត

អនុម័តដោយសមាជិកក្រុមប្រឹក្សាជាតិ នៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត

កិច្ចប្រជុំផ្លូវការថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០១៤

សាលារាជធានីភ្នំពេញ

# ក្រមសីលធម៌ - សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត

## ១. គោលបំណង

ក្រមសីលធម៌សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ដែលក្រុមប្រឹក្សារាជធានី ខេត្ត គឺជាសមាជិករបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត (ស.ជ.ក.រ.ខ) គឺជាការដាក់ចេញនូវលក្ខខណ្ឌកម្រិតអប្បបរមាស្តីពីឥរិយាបថ និងការអនុវត្តរបស់សមាជិកក្រុមប្រឹក្សា សំដៅលើកស្ទួយតម្លៃ និងសេចក្តីថ្លៃថ្នូរដល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួនស្របទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ច្បាប់រៀបចំអង្គការ ២០០៨) វិធានផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ច្បាប់[1] ឯកសារពាក់ព័ន្ធ[2] និងគោលការណ៍ណែនាំផ្សេងៗ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រដល់ការរៀបចំផែនការ និងថវិកាអភិវឌ្ឍន៍ក្នុងមូលដ្ឋាន។

ក្រមសីលធម៌នេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងគាំទ្រដល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ដូចជា ÷

- *ស្វែងយល់ពីបទដ្ឋានស្តីពីការប្រព្រឹត្ត (ការស្តែងចេញជាសកម្មភាព) និងឥរិយាបថថ្លៃថ្នូរ ដែលរំពឹងថាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត គោរព និងប្រតិបត្តិតាម*
- *ផ្តល់លទ្ធភាពឱ្យសមាជិកក្រុមប្រឹក្សារាជធានី ខេត្តបំពេញតាមភារកិច្ច ដែលត្រូវបានកំណត់ក្នុងលក្ខន្តិកៈ ធ្វើសកម្មភាពប្រកបដោយភាពស្មោះត្រង់ និងយកចិត្តទុកដាក់លើភាពត្រឹមត្រូវក្នុងកម្រិតមួយសមស្របនៅពេលបំពេញភារកិច្ចរបស់ខ្លួន*
- *ធ្វើសកម្មភាពតាមបែបផែនមួយសំដៅបង្កើនទំនុកចិត្តរបស់សាធារណជន និងប្រជាពលរដ្ឋលើសុចរិតភាពរបស់រដ្ឋបាលថ្នាក់មូលដ្ឋាន*
- *លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការងាររបស់ក្រុមប្រឹក្សា*

[1] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨) និងច្បាប់ផ្សេងទៀត

[2] ធម្មនុញ្ញនៃក្រុមប្រឹក្សារាជធានី ខេត្ត គោលការណ៍ណែនាំអំពីការរៀបចំផែនការរាជធានី ខេត្ត និងឯកសារ PIM ជាដើមទៀត

## ២. ការទទួលខុសត្រូវ និងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាដែលច្បាប់បានកំណត់

រាជធានី និងខេត្ត គឺជានីតិបុគ្គល នៃនីតិសាធារណៈ[3]។ នីតិបុគ្គលនីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយជាតំណាង ហើយត្រូវបានបោះឆ្នោតជ្រើសរើសដោយស្របច្បាប់[4]។

ការទទួលខុសត្រូវ និងភារកិច្ចកំណត់ដោយច្បាប់របស់សមាជិកក្រុមប្រឹក្សារដ្ឋបាលមូលដ្ឋាន នៅថ្នាក់រាជធានី និងខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា គឺស្ថិតក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨[5]។

ក្រុមប្រឹក្សារាជធានី ខេត្ត ផ្តល់ការដឹកនាំដល់ប្រជាពលរដ្ឋ ឬរាជធានី ខេត្តរបស់ខ្លួន ដោយមានសមាសភាពសុទ្ធតែជាតំណាង (សមាជិកក្រុមប្រឹក្សាដែលបានជ្រើសរើសតាមរយៈការបោះឆ្នោត) មានភារៈបំពេញការងាររួមគ្នាដើម្បីគ្រប់គ្រងរាជធានី ខេត្តរបស់ខ្លួន។ សមាជិកក្រុមប្រឹក្សារដ្ឋបាលមូលដ្ឋានប្រភេទដទៃ ដែលបានជ្រើសរើសដោយការបោះឆ្នោតត្រូវចូលរួមចំណែកជាមួយក្រុមប្រឹក្សារាជធានី ខេត្ត សំដៅបង្កើត និងលើកកម្ពស់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យប្រកបដោយនិរន្តរភាព ដែលក្នុងនោះមាន៖

- *ភាពជាតំណាងសាធារណៈ*
- *ស្វ័យភាពរបស់មូលដ្ឋាន*
- *ការពិគ្រោះយោបល់ និងការចូលរួម*
- *ការឆ្លើយតប និងគណនេយ្យភាព*
- *ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនក្នុងមូលដ្ឋាន*
- *ការលើកស្ទួយសមធម៌*
- *តម្លាភាព និងសុចរិតភាព*
- *វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច*

រាជធានី ខេត្ត ត្រូវបានគ្រប់គ្រងស្របទៅតាមគោលការណ៍រដ្ឋបាលឯកភាព សំដៅបង្កើនការលើកកម្ពស់ និងរក្សានិរន្តរភាពការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ តាមរយៈគោលនយោបាយជាតិស្តីពីវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា។

---

[3] មាត្រា ១០ និង ១១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ២០០៨

[4] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ

[5] ជាពិសេស មាត្រា ១៧, ២៩-៥២

# ៣. គោលការណ៍ក្រមសីលធម៌

សមាជិកក្រុមប្រឹក្សាត្រូវរៀបចំឥរិយាបថខ្លួនឯង ហើយអនុវត្តមុខងារ និងកិច្ចការនានារបស់ក្រុមប្រឹក្សាតាមបែបផែនមួយដែលធ្វើឱ្យប្រជាពលរដ្ឋ និងសហគមន៍នៅតែមានការជឿជាក់ និងមានទំនុកចិត្តចំពោះក្រុមប្រឹក្សា។ គោលការណ៍ខាងក្រោម បង្ហាញពីការអនុវត្តប្រកបដោយក្រមសីលធម៌ ដែលសមាជិកក្រុមប្រឹក្សាត្រូវប្រកាន់ខ្ជាប់នៅពេលបំពេញភារកិច្ចរបស់ខ្លួន។

## ១. ការបំពេញការងារទទួលបានលទ្ធផលខ្ពស់

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវផ្តល់សេវាក្នុងកម្រិតស្តង់ដាខ្ពស់បំផុតតាមដែលអាចធ្វើបានជូនដល់សាធារណជនទូទៅ និងផ្តល់ការគាំទ្រ ក៏ដូចជាផ្តល់ដំបូន្មានសមស្រប មិនលំអៀងដល់ប្រជាពលរដ្ឋ និងសហគមន៍។ សមាជិកក្រុមប្រឹក្សា ទទួលខុសត្រូវលើការកំណត់ចក្ខុវិស័យ និងទិសដៅសម្រាប់សហគមន៍។ លើកកម្ពស់អភិបាលកិច្ចល្អ គ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិនានារបស់ក្រុមប្រឹក្សា ដើម្បីបំពេញតម្រូវការរបស់សហគមន៍ទាំងពេលបច្ចុប្បន្ន ទាំងពេលអនាគត ក្នុងស្មារតីជម្រុញលើកកម្ពស់ការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច និងធ្វើឱ្យមានតុល្យភាពរវាងតម្រូវការ និងផលប្រយោជន៍របស់សហគមន៍ ក្នុងរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ក៏ដូចជាគោរពផលប្រយោជន៍ជាតិទាំងមូល។

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងសេចក្តីសម្រេច និងសកម្មភាពរបស់ខ្លួន ហើយត្រូវដាក់ចិត្តដាក់កាយទទួលយករាល់ការទិទៀនទាំងឡាយស័ក្តិសមក្នុងមុខតំណែងជាក្រុមប្រឹក្សា។ សហគមន៍មានសិទ្ធិរំពឹងថា៖ ខ្លួននឹងទទួលបានសេវាក្នុងកម្រិតស្តង់ដាខ្ពស់បំផុតពីរាល់សមាជិកក្រុមប្រឹក្សាទាំងអស់ ក៏ដូចជាពីអ្នកដែលពាក់ព័ន្ធនឹងការងាររបស់ក្រុមប្រឹក្សា។ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវប្រកាន់ខ្ជាប់ឱ្យបានត្រឹមត្រូវតាមស្តង់ដានៃសុចរិតភាពការងារ និងគិតគូរពីផលប្រយោជន៍ផ្នែកអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចរបស់សហគមន៍មូលដ្ឋាន។

## ២. ការធ្វើសេចក្តីសម្រេចចិត្ត តាមរយៈការចូលរួមផុសផុល

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវធ្វើសកម្មភាព និងធ្វើសេចក្តីសម្រេចចិត្តតាមបែបផែនមួយសំដៅលើកកម្ពស់ការការពារសិទ្ធិប្រជាពលរដ្ឋ ដូចដែលមានចែងក្នុងមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញ *"សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលបានការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ"* ។

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវជម្រុញឱ្យមានការចូលរួម និងការពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋ សហគមន៍ សង្គមស៊ីវិល វិស័យឯកជន គណៈកម្មការនានា និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីគាំទ្រដល់សេចក្តីសម្រេចចិត្ត តាមរយៈវេទិកាសាធារណៈ ដើម្បីធានាយ៉ាងណាឱ្យរាល់សេចក្តីសម្រេចទាំងអស់ធ្វើឡើងយ៉ាងត្រឹមត្រូវ និងមានប្រសិទ្ធិភាពខ្ពស់។ ដើម្បីសម្រេចគោលបំណងនេះ សមាជិកក្រុមប្រឹក្សារាជធានី

ខេត្ត ត្រូវធានាថា៖ គ្រប់ភាគីពាក់ព័ន្ធទាំងអស់មានឱកាសគ្រប់គ្រាន់លើកឡើងពីទស្សនៈយល់ឃើញរបស់ពួកគេ សំដៅជួយដោះស្រាយកង្វល់ និងជម្រុញការឆ្លើយតបរបស់ក្រុមប្រឹក្សាចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានប្រកបដោយភាពយុត្តិធម៌ និងស្មើភាពគ្នា។

### ៣. លើកកម្ពស់ការជឿទុកចិត្ត

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវលើកកម្ពស់ការជឿទុកចិត្តតាមរយៈការអនុវត្តសកម្មភាពផ្សេងៗ ប្រកបដោយភាពស្មោះត្រង់ និងធានាថា៖ ធនធានសាធារណៈប្រើប្រាស់ដោយភាពមធ្យ័តខ្ពស់ ហើយស្របនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន។

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបញ្ចៀសជាដាច់ខាត មិនឱ្យមានករណីសង្ស័យពីទង្វើណាមួយ ដែលមិនត្រឹមត្រូវនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាលើកិច្ចអភិវឌ្ឍន៍ ដែលនាំឱ្យមានការមិនជឿទុកចិត្តគ្នានៅក្នុងជួរក្រុមប្រឹក្សា និងនៅក្នុងការងាររបស់ក្រុមប្រឹក្សា។ ដើម្បីបញ្ចៀសបានរាល់ការសង្ស័យ សមាជិកក្រុមប្រឹក្សាមិនត្រូវមានសកម្មភាព សេចក្តីថ្លែង ឬការប្រាស្រ័យទាក់ទងណាមួយ ជាមួយអ្នកដែលពាក់ព័ន្ធនឹងការកំណត់អាទិភាពកិច្ចអភិវឌ្ឍន៍ ឬបង្ហាញពីការសុខចិត្តផ្តល់សម្បទានដោយមិនត្រឹមត្រូវ ឬបង្កភាពអនុគ្រោះដល់អ្នកដែលពាក់ព័ន្ធទាំងនេះឡើយ។

### ៤. លើកកម្ពស់សមភាព

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបំពេញការងារស្របទៅតាមមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា សំដៅការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋខ្មែរទាំងពីរភេទក្នុង “ការចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រទេសជាតិ” ច្បាប់នានា វិធាន និងនីតិវិធីបានបង្កើតឡើង ដោយមិនលំអៀង និងដោយគ្មានការរើសអើង។

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវប្រតិបត្តិចំពោះសមាជិកសហគមន៍គ្រប់រូប ដែលពួកគេមានសិទ្ធិទទួលបានសេវាពីក្រុមប្រឹក្សាដោយស្មើភាព គ្មានការរើសអើង ឬការយាយីពីបុគ្គលណាម្នាក់ ឬក្រុមសហគមន៍ណាមួយឡើយ។ សមាជិកក្រុមប្រឹក្សាត្រូវប្រតិបត្តិប្រកបដោយការគោរពចំពោះប្រជាពលរដ្ឋ ដោយមិនគិតពីភេទ ពូជសាសន៍ អាយុ សាសនា ការមានផ្ទៃពោះ ពិការភាព ឬការប្រកាន់និន្នាការនយោបាយឡើយ។

### ៥. ធានានូវភាពមានពេលវេលា

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវចេះរៀបចំបែងចែកកម្លាំង និងពេលវេលាក្នុងចំណោមសមាជិកក្រុមប្រឹក្សា ដើម្បីចូលរួមក្នុងវេទិកាសាធារណៈ និងជួបជាមួយប្រជាពលរដ្ឋទៀងទាត់តាមពេលកំណត់។ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវរៀបចំសវនាការជាសារណៈឱ្យបានមួយដងក្នុងមួយខែ។ សមាជិកក្រុម

ប្រឹក្សារាជធានី ខេត្ត មានកាតព្វកិច្ចតាមច្បាប់ ក្នុងការត្រៀម និងរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ប្រកបដោយលក្ខណៈ វិជ្ជាជីវៈ ប្រជាធិបតេយ្យ ជាសាធារណៈ (ដោយចំហរ) និងមានការចូលរួមយ៉ាងសកម្ម។

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវទុកពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើការឆ្លើយតបឱ្យបានទាន់ពេលវេលាចំពោះកង្វល់ និងសេចក្តីត្រូវការរបស់ក្រុមប្រឹក្សាដទៃ (ក្រុមប្រឹក្សាស្រុក ក្រុង ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់) ប្រជាពលរដ្ឋ សមាជិកសហគមន៍ សង្គមស៊ីវិល និងវិស័យឯកជន នៅក្នុងរាជធានី ខេត្ត សំដៅស្វែងរកដំណោះស្រាយ ឬឆ្លើយតបទៅនឹងសំណើសុំសេវាក្តី ក្តីបារម្ភក្តី និងតម្រូវការដែលបានលើកឡើងក្នុងវេទិកាសាធារណៈ ឬក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្តក្តី។

## ៦. ទំនាក់ទំនងការងារល្អ

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវធានាឱ្យបាននូវកិច្ចទំនាក់ទំនងល្អជាមួយប្រធានក្រុមប្រឹក្សា ជាមួយសមាជិកក្រុមប្រឹក្សាដទៃទៀត ជាមួយសមាជិកគណៈកម្មាធិការនានា (ដែលបានបង្កើតឡើងដោយក្រុមប្រឹក្សារាជធានី ខេត្ត) គណៈអភិបាល មន្ទីរជំនាញ ប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុក ក្រុង ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ អង្គការសង្គមស៊ីវិល និងវិស័យឯកជន នៅក្នុងរាជធានី ខេត្ត សំដៅបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

សមាជិកក្រុមប្រឹក្សា ត្រូវបង្ហាញការគោរពចំពោះប្រធានក្រុមប្រឹក្សា និងសមាជិកក្រុមប្រឹក្សាដទៃទៀត ក៏ដូចជាសមាជិកសហគមន៍ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា និងវេទិកាផ្សេងៗ ដែលបានរៀបចំឡើងដោយក្រុមប្រឹក្សា។ សមាជិកក្រុមប្រឹក្សាទាំងអស់ត្រូវធានាថា÷ រាល់អ្នកចូលរួមទាំងអស់ក្នុងព្រឹត្តិការណ៍ខាងលើនេះ (កិច្ចប្រជុំ ឬវេទិកា) បានបញ្ចេញមតិយោបល់ដោយសេរី និងផ្តល់ឱកាសឱ្យមានការលើកឡើងពីគំនិតយោបល់ដោយពុំមានការរំខាន។

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវចៀសវាងការបង្ករឡើងនូវស្ថានភាពមិនល្អ ឬបរិយាកាសអាប់អួរក្នុងកំឡុងពេលការបំពេញមុខងារជាក្រុមប្រឹក្សា និងនៅតាមវេទិកាសាធារណៈដូចជា÷ សមាជិកក្រុមប្រឹក្សាបង្អាប់បញ្ឆាសមាជិកក្រុមប្រឹក្សាគ្នាឯង តាមរយៈការបញ្ចុះបញ្ចូល (ការប៉ុនប៉ង) តាមរយៈឥទ្ធិពលដោយផ្ទាល់ ឬការដាក់សម្ពាធជាដើម។ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត មិនត្រូវប្រព្រឹត្តទង្វើណា ដែលនាំឱ្យប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងស្ថាប័នវិស័យឯកជន ជឿថា÷ ពួកគេអាចនឹងទទួលបានភាពអនុគ្រោះពីសេចក្តីសម្រេច របស់ក្រុមប្រឹក្សាឡើយ។

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវរៀបចំវេទិកាសមស្របសំដៅពង្រឹងកិច្ចសហប្រតិបត្តិការ និងតម្រឹមប្រយោជន៍របស់រាជធានី ខេត្ត ឱ្យស្របជាមួយនឹងប្រយោជន៍របស់ស្រុក ក្រុង ខណ្ឌ ឃុំ និងសង្កាត់ នៅ

ក្នុងរាជធានី ខេត្ត។ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត មិនត្រូវប៉ុនប៉ងជ្រៀតជ្រែក នៅក្នុងកិច្ចការរបស់ក្រុមប្រឹក្សាស្រុក ក្រុង ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងរាជធានី ខេត្ត ឡើយ។

## ៧. ជៀសវាងនូវទំនាស់ផលប្រយោជន៍

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត មិនត្រូវប្រើប្រាស់មុខតំណែងផ្លូវការរបស់ខ្លួន ដើម្បីការទាញយកផលប្រយោជន៍ទោះជាក្នុងទម្រង់ណាក៏ដោយ ដូចជា÷ ផលប្រយោជន៍សម្រាប់បុគ្គលក្តី សម្រាប់វិជ្ជាជីវៈក្តី សម្រាប់ធុរកិច្ចផ្ទាល់ខ្លួនក្តី សម្រាប់អ្នកដទៃទៀតដែលខ្លួនមានទំនាក់ទំនងក្តី ឬទំនាក់ទំនងជាមួយគ្រួសារខ្លួនក្តី។ ចំណុចនេះក៏ពាក់ព័ន្ធផងដែរជាមួយនឹងការផ្តល់ដំបូន្មាន ឬតម្រុយដល់សមាជិកគ្រួសារខ្លួន និងឬមិត្តភក្តិរបស់ខ្លួន ពាក់ព័ន្ធជាមួយនឹងការងារផ្លូវការរបស់ក្រុមប្រឹក្សា ឬតាមរយៈប្រជាសហព័ន្ធឡើយ។ សមាជិកក្រុមប្រឹក្សារាជធានី ខេត្តទាំងអស់ ត្រូវចៀសវាងការពាក់ព័ន្ធជាមួយនឹងទំនាស់ផលប្រយោជន៍ ហើយត្រូវគ្រប់គ្រងទំនាស់ផលប្រយោជន៍ឱ្យបានល្អប្រសើរ។

ទំនាស់ផលប្រយោជន៍កើតមានឡើង នៅពេលដែលសហគមន៍ ឬពលរដ្ឋទទួលបានព័ត៌មានច្បាស់លាស់ថា÷ សមាជិកក្រុមប្រឹក្សាណាម្នាក់ទទួលប្រយោជន៍ឯកជនអ្វីមួយនៅពេលបំពេញការងារជាក្រុមប្រឹក្សារាជធានី ខេត្ត។

ទំនាស់ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ សំដៅលើផលប្រយោជន៍ដែលសមាជិកក្រុមប្រឹក្សាណាម្នាក់ទទួលបានផលកម្រៃផ្នែកហិរញ្ញវត្ថុក្នុងកិច្ចការអ្វីមួយ។ សមាជិកក្រុមប្រឹក្សាម្នាក់នឹងត្រូវបានចាត់ទុកថាមានទំនាស់ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ប្រសិនបើសហព័ន្ធរបស់ខ្លួន សមាជិកគ្រួសារ សាច់ញាតិ ឬមិត្តភក្តិជិតដិតណាម្នាក់ ទទួលបានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពីការងារ ឬកិត្តនាមរបស់ក្រុមប្រឹក្សា។ សមាជិកក្រុមប្រឹក្សាត្រូវតែធ្វើការប្រកាសជាលាយលក្ខណ៍អក្សរចំពោះប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឬក្នុងករណីប្រធានក្រុមប្រឹក្សាត្រូវធ្វើការប្រកាសជាលាយលក្ខណ៍អក្សរចំពោះក្រសួងមហាផ្ទៃ អំពីផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុទាំងឡាយដែលអាចមានទំនាស់ផលប្រយោជន៍ជាមួយនឹងការងារ និងកេរ្តិ៍ឈ្មោះរបស់ក្រុមប្រឹក្សា។ សមាជិកក្រុមប្រឹក្សាដែលធ្វើឱ្យបែកធ្លាយកិច្ចការសម្ងាត់របស់ក្រុមប្រឹក្សា មិនត្រូវចូលរួមក្នុងកិច្ចប្រជុំ ឬក្នុងការពិភាក្សា ឬចូលរួមបោះឆ្នោតសម្រេចចិត្តលើបញ្ហានោះឡើយ ។

សមាជិកក្រុមប្រឹក្សាណាក៏ដោយ ត្រូវតែប្រកាសចំពោះប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ហើយក្នុងករណីប្រធានក្រុមប្រឹក្សាត្រូវធ្វើការប្រកាសជាលាយលក្ខណ៍អក្សរចំពោះក្រសួងមហាផ្ទៃ អំពីផលប្រយោជន៍មិនមែនហិរញ្ញវត្ថុទាំងឡាយ ដែលអាចនាំឱ្យមានទំនាស់ផលប្រយោជន៍របស់ក្រុមប្រឹក្សា ឬការបង្កើតឱ្យមានការចាប់អារម្មណ៍នៅក្នុងសហគមន៍ថា÷ សមាជិកក្រុមប្រឹក្សារូបនោះកំពុងប្រើប្រាស់មុខតំណែងរបស់ខ្លួនក្នុងនាមជាសមាជិកក្រុមប្រឹក្សាទាញយកប្រយោជន៍ជាបុគ្គល ឬប្រយោជន៍សម្រាប់គ្រួសារ ឬប្រយោជន៍របស់

មិត្តភក្តិណាម្នាក់ឡើយ។ "ផលប្រយោជន៍មិនមែនហិរញ្ញវត្ថុ" គឺជាការទាញយកផលចំណេញផ្នែកនយោបាយក្តី ការពង្រីក ឬការពង្រឹងឥទ្ធិពលផ្ទាល់ខ្លួនក្តី ឬការទាញយកផលចំណេញលើវិជ្ជាជីវៈក្តី ឬក៏ការបំផ្លិចបំផ្លាញសេចក្តីថ្លៃថ្នូរ និងកេរ្តិ៍ឈ្មោះរបស់ក្រុមប្រឹក្សា។[6]

## ៨. ការបញ្ចុះបញ្ចូលត្រឹមត្រូវ

ក្រុមមនុស្ស បុគ្គលម្នាក់ៗ អង្គការ ស្ថាប័ន ក្រុមហ៊ុន និងសង្គមស៊ីវិល អាចធ្វើការបញ្ចុះបញ្ចូលសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត បាន។ បុគ្គលណាក៏ដោយ អាចមានលទ្ធភាពបញ្ចុះបញ្ចូលក្រុមប្រឹក្សា ឬសមាជិកក្រុមប្រឹក្សាណាម្នាក់បាន។ សមាជិកក្រុមប្រឹក្សាត្រូវបានអនុញ្ញាតឱ្យស្តាប់ពីខ្លឹមសារលើកឡើងដោយអ្នកបញ្ចុះបញ្ចូល ហើយពាំនាំចំណុចទាំងនេះ ដោយមិនលំអៀងប្រាប់ដល់ក្រុមប្រឹក្សា ហើយជៀសវាងការទាញជាសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួន ឬផ្តល់មតិយោបល់ឯកភាពផ្ទាល់ខ្លួនជាមួយនឹងអ្នកបញ្ចុះបញ្ចូលនេះ។ សមាជិកក្រុមប្រឹក្សាត្រូវរាយការណ៍ដល់សមាជិកក្រុមប្រឹក្សាដទៃ និងរាយការណ៍ដល់ប្រធានក្រុមប្រឹក្សារាជធានី ខេត្តអំពីខ្លឹមសារនៃការបញ្ចុះបញ្ចូល។

នៅពេលដែលសមាជិកក្រុមប្រឹក្សាទទួលបានការបញ្ចុះបញ្ចូលពាក់ព័ន្ធនឹងការរៀបចំផែនការអភិវឌ្ឍន៍ សមាជិកក្រុមប្រឹក្សារូបនេះត្រូវតែបញ្ជាក់ពីជំហរឱ្យបានច្បាស់លាស់ថា÷ ខ្លួនមិនស្ថិតនៅក្នុងតំណែងអ្វីមួយដើម្បីផ្តល់ការគាំទ្រ ឬប្រឆាំងនឹងសំណើដែលលើកឡើងទាក់ទងនឹងការរៀបចំផែនការក្តី ឬការផ្តល់កិច្ចសន្យាក្តីសម្រាប់គម្រោងអភិវឌ្ឍន៍ឡើយ។

## ៩. លើកកម្ពស់ភាពបើកចំហ និងជម្រុញការលើកយោបល់ជាសាធារណៈ

កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាពាក់ព័ន្ធជាមួយថវិកា ការសម្រេចចិត្ត និងឯកសារបោះពុម្ពនានា (ជាទូទៅ) ត្រូវផ្សព្វផ្សាយដោយបើកចំហចំពោះសហគមន៍ ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ជាពិសេសនៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងការធ្វើលទ្ធកម្មសេវាកម្ម។ ក្រុមប្រឹក្សារាជធានី ខេត្តត្រូវបង្កើតលក្ខខណ្ឌអំណោយផលដើម្បីផ្សព្វផ្សាយព័ត៌មានស្តីអំពីសេចក្តីសម្រេច របាយការណ៍ របៀបវារៈកិច្ចប្រជុំ លក្ខន្តិកៈ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ លិខិតបទដ្ឋាន និងប្រកាសនានា ពាក់ព័ន្ធជាមួយនឹងការងាររបស់ក្រុមប្រឹក្សា រួមទាំងឯកសារផ្សេងទៀតរបស់ក្រុមប្រឹក្សា។ ក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវប្រើ

[6] ឧទាហរណ៍អំពីឥរិយាបថគ្មានតម្លៃ រួមមាន ឥរិយាបថគ្មានរបៀបរបប ការប្រើបំពានជាតិស្រវឹង និងគ្រឿងញៀន ការលេងល្បែងស៊ីសងជាសាធារណៈ និងការទំនាក់ទំនង ឬការចេញបញ្ជា ដោយគ្មានការអនុញ្ញាត (តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា) ទៅឱ្យអ្នកម៉ៅការ ឬអ្នកចូលរួមដេញថ្លៃរបស់ក្រុមប្រឹក្សា ការផ្សព្វផ្សាយពីរបៀបវារៈនយោបាយ ដែលនាំឱ្យមាន ឬជ្រៀតជ្រែកជាមួយនឹងដំណើរការការងារប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុមប្រឹក្សាស្រុក ក្រុង ខណ្ឌ ឬក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានទីតាំងនៅក្នុងរាជធានី ខេត្ត។

ប្រាស់ក្តារខៀនព័ត៌មានសាធារណៈ ជាមធ្យោបាយសម្រាប់ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ និងសហគមន៍ដែលខ្លួនធ្វើជាតំណាងផងដែរ។

ក្នុងករណីតម្រូវឱ្យរក្សាការសម្ងាត់ផ្ទៃក្នុងរបស់ក្រុមប្រឹក្សា សមាជិកនីមួយៗត្រូវគោរពតាម និងរក្សាការសម្ងាត់ឱ្យបាន។ នៅក្នុងករណីដែលសមាជិកក្រុមប្រឹក្សាទទួលបានព័ត៌មានពីស្ថាប័នរដ្ឋបាលនៅថ្នាក់ជាតិដែលមានលក្ខណៈឯកជនភាព ឬជាព័ត៌មានសម្ងាត់មិនតម្រូវឱ្យផ្សព្វផ្សាយជាសាធារណៈ សមាជិកក្រុមប្រឹក្សាជានិច្ចកាលត្រូវតែគោរព និងអនុវត្តទៅតាមល័ក្ខខ័ណ្ឌនេះ (ផ្ទាល់មាត់ក្តី ឬជាលាយលក្ខណ៍អក្សរក្តី)។

ច្បាប់រៀបចំអង្គការ (២០០៨) អនុញ្ញាតឱ្យក្រុមប្រឹក្សារៀបចំកិច្ចប្រជុំសំងាត់ ដែលអាចផ្តល់ព័ត៌មានបានចំពោះតែសមាជិកក្រុមប្រឹក្សា ហើយមិនតម្រូវឱ្យផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ សហគមន៍ សង្គមស៊ីវិល និងភាគីផ្សេងទៀតឡើយ។ ព័ត៌មានទាំងនេះមិនត្រូវបង្ហាញឱ្យដឹង ឬប្រើប្រាស់តាមបែបផែនអ្វីមួយដើម្បីទទួលបានប្រយោជន៍បុគ្គល ឬប្រយោជន៍គណបក្ស ឬដែលនាំឱ្យក្រុមប្រឹក្សាអាប់ឱនកិត្តិយសនោះឡើយ។

សមាជិកក្រុមប្រឹក្សា ត្រូវតែចែករំលែកព័ត៌មានតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងវិភាគលើសេចក្តីសម្រេច ការកសាងផែនការសកម្មភាព និងថវិកា ឬការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

## ១០. ការរាយការណ៍ពីការបំពានក្រមសីលធមិ

នៅក្នុងករណី ដែលមានការបំពានមាត្រានានានៅក្នុងក្រមសីលធមិនេះ ក្រុមប្រឹក្សាត្រូវយកច្បាប់រៀបចំអង្គការ (ឆ្នាំ២០០៨) និងវិធានផ្ទៃក្នុងរបស់ក្រុមប្រឹក្សាមកធ្វើជាសេចក្តីសំអាង ឬយោង។ ក្នុងករណីដែលមានការបំពានក្រមសីលធមិ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវជូនដំណឹងដល់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ជាលាយលក្ខណ៍អក្សរស្តីពីការបំពាន ហើយវិធានការណ៍នានា នឹងត្រូវពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាជាតិ នៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ។

## ៤. សេចក្តីប្រកាស

យើងខ្ញុំសូមប្រកាសថា នឹងអនុវត្តសកម្មភាពទាំងឡាយតាមបែបផែនដើម្បីជម្រុញ និងរក្សាឱ្យបាននូវភាពជឿទុកចិត្ត និងសុចរិតភាពរបស់ក្រុមប្រឹក្សា ក្នុងពេលបំពេញការងារតាមរយៈ

- *ធ្វើសកម្មភាពដោយស្របច្បាប់ ដោយភាពស្មោះត្រង់ តម្លាភាព និងប្រកាន់ខ្ជាប់ទៅតាមច្បាប់រៀបចំអង្គការ (២០០៨) បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា សេចក្តីណែនាំពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រមសីលធម៌សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ឯកសារ និងល័ក្ខខ័ណ្ឌតម្រូវដោយផ្នែករដ្ឋបាលពាក់ព័ន្ធដទៃទៀត*
- *យកចិត្តទុកដាក់ និងការពិនិត្យលើភាពត្រឹមត្រូវក្នុងកម្រិតមួយសមស្រប នៅពេលបំពេញមុខងារជាក្រុមប្រឹក្សា និងបំពេញការងារប្រកបដោយប្រសិទ្ធភាព នៅក្នុងក្របខ័ណ្ឌរបស់ក្រុមប្រឹក្សា*
- *ប្រព្រឹត្តសកម្មភាពដោយត្រឹមត្រូវ ប្រកបដោយក្រមសីលធម៌ និងចៀសវាងការរំលោភអំណាច ឬការរើសអើង*
- *គោរពតាមគោលការណ៍ ដូចមានចែងនៅក្នុងក្រមសីលធម៌នេះ*

នៅគ្រប់ពេលទាំងអស់ យើងខ្ញុំនឹងមិនសម្តែងនូវឥរិយាបថទាំងឡាយណាដែលប្រជាពលរដ្ឋ សហគមន៍ ឬសមាជិកក្រុមប្រឹក្សាផ្សេងទៀតចាត់ទុកថាមានទំនាស់ជាមួយនឹងផលប្រយោជន៍របស់ក្រុមប្រឹក្សា ឬធ្វើសកម្មភាពណាមួយដែលនាំឱ្យប៉ះពាល់ដល់តម្លៃរបស់ក្រុមប្រឹក្សា ក្នុងពេលកាន់តំណែងជាសមាជិកក្រុមប្រឹក្សាឡើយ។

ក្នុងនាមក្រុមប្រឹក្សាជាតិ នៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា

...............................................

**ឯកឧត្តម ណាំ ទុំ**

**ប្រធានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត**

កាលបរិច្ឆេទ÷ ២៨ មេសា ២០១៤

ទីកន្លែង÷ សាលប្រជុំសាលារាជធានីភ្នំពេញ